អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន
# ជនជាប់ចោទ អៀង ធីរិទ្ធ ត្រូវបានដោះលែងជាមួយលក្ខខណ្ឌបណ្តោះអាសន្ន

ប្រធានអង្គជំនុំជម្រះតុលាការកំពូលនៃអ.វ.ត.ក ដោយអនុលោមតាមវិធាន ៨២(៦) នៃវិធានផ្ទៃក្នុង ធ្វើការសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំផ្អាកសេចក្តីសម្រេចដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយគ្មានលក្ខខណ្ឌរបស់អង្គជំនុំជម្រះសាលាដំបូង ដោយសម្រេចថាៈ អៀង ធីរិទ្ធត្រូវបានដោះលែងជាមួយលក្ខខណ្ឌបណ្តោះអាសន្នមួយចំនួនដូចជា៖

១-ជនជាប់ចោទត្រូវជូនដំណឹងដល់អង្គជំនុំជម្រះអំពីអាសយដ្ឋានដែលខ្លួនត្រូវស្នាក់នៅ ហើយមិនត្រូវផ្លាស់ប្តូរទីលំនៅដោយមិនមានការអនុញ្ញាតពីអង្គជំនុំជម្រះឡើយ។

២-ជនជាប់ចោទត្រូវប្រគល់លិខិតឆ្លងដែន និងឯកសារធ្វើដំណើរពាក់ព័ន្ធដទៃទៀត ហើយមិនត្រូវចេញក្រៅព្រំប្រទល់ដែនដីនៃព្រះរាជាណាចក្រកម្ពុជាឡើយ។

៣-ជនជាប់ចោទត្រូវគោរពតាមដីកាកោះដែលចេញដោយតុលាការ។

វិធានការបណ្តោះអាសន្ននេះ មានសុពលភាពរហូតដល់អង្គជំនុំជម្រះតុលាការកំពូលចេញសេចក្តីសម្រេចទាំងស្រុងលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

http://www.eccc.gov.kh/sites/default/files/documents/courtdoc/E138_1_10_1_2_1_KH.pdf

**16 September 2012**

# PRESS RELEASE
# IENG THIRITH RELEASED WITH PROVISIONAL CONDITIONS

The President of the Supreme Court Chamber, acting pursuant to the Internal Rule 82 (6), deciding on the request to stay the Trial Chamber's order to release unconditionally Accused Ieng Thirith, ruled that Ieng Thirith be released on the following provisional conditions:

1-The Accused shall inform the Chamber of the address where she will reside and not change residence without prior authorisation from the Chamber;
2-The Accused shall surrender her passport and any other travel documents, and remain in the territory of the Kingdom of Cambodia;
3-The Accused shall response to any summon issued by the Court;

This is a provisional measure that will remain in effect until the Supreme Court Chamber decides on the merits of the appeal by the Co-Prosecutors.

http://www.eccc.gov.kh/sites/default/files/documents/courtdoc/E138_1_10_1_2_1_EN.pdf